**សម្ដេចពិជ័យសេនា ទៀ បាញ់**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សូមគោរពជូន**
**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**
**និងសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និងសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាទីគោរពដ៏ខ្ពង់ខ្ពស់

ខ្ញុំបាទ និងភរិយា សូមចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំដោយអ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកា ធម្មញ្ញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** ត្រូវជាម្ដាយបង្កើត ម្ដាយក្មេក សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និងសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានទទួលមរណភាព នៅថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង០២:១២នាទីទៀបភ្លឺ ដោយជរាពាធ ក្នុងជន្មាយុ៩៦ឆ្នាំ ។

មរណភាពរបស់អ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកា ធម្មញ្ញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** គឺជាការបាត់បង់មាតា ជីដូន ជីទួត ប្រកបដោយព្រហ្មវិហារធម៌ ដែលបានបូជានូវកម្លាំងកាយពល និងបញ្ញាញាណ ក្នុងការចិញ្ចឹមបីបាច់បុត្រធីតារបស់មហាឧបាសិកា ចាប់តាំងពីប្រសូត្រពីផ្ទៃរហូតធំដឹងក្ដី មានកេរ្ដិ៍ឈ្មោះរបោះសម្លេងក្នុងសង្គម និងក្លាយជាគ្រួសារដែលប្រជាពលរដ្ឋកម្ពុជាទូទៅគោរពស្រឡាញ់ និងជាគ្រួសារមួយដែលតែងតែមានព្រហ្មវិហាធម៌សណ្ដោសប្រោសប្រណីដល់មនុស្សផងទាំងពួង តាមរយៈកាយវិកាយ និងកិច្ចការមនុស្សធម៌ធ្វើបុណ្យចែកទាន និងកសាងនូវសមិទ្ធផលសង្គមជាច្រើនរាប់មិនអស់ចាប់តាំងពីទីក្រុងរហូតដល់ទីជនបទឆ្ងាយដាច់ស្រយាល។ សេចក្ដីល្អ និងគុណធម៌ដ៏ឧត្តុង្គឧត្តមនេះ នឹងឋិតនៅក្នុងការចងចាំរបស់កូនចៅ ចៅទួត និងញាតិមិត្តទាំងអស់គ្មានថ្ងៃបំភ្លេចបានឡើយ។

ក្នុងឱកាស មានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំបាទ និងភរិយា សូមចូលរួមរំលែកទុក្ខនូវមរណទុក្ខដោយក្ដីស្រណោះ និងការអាឡោះអាល័យជាមួយសម្ដេច បុត្រា បុត្រី ជីដូន ជីទួត ព្រមទាំងបងប្អូនទាំងអស់នៃសព ដោយសេចក្ដីសង្វេគជាទីបំផុត និងសូមឧទ្ទិសបួងសួងឲ្យដួងវិញ្ញាណក្ខន្ធអ្នកឧកញ៉ា ព្រឹទ្ធមហាឧបាសិកា ធម្មញ្ញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** បានចាប់កំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និងសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំបាទនិងភរិយា ។

ថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០

**ទៀ បាញ់**